NEWS RELEASE

UNITED NATIONS HUMAN RIGHTS SPECIAL PROCEDURES
SPECIAL RAPPORTEURS, INDEPENDENT EXPERTS & WORKING GROUPS

# ក្រុមអ្នកជំនាញ អ.ស.ប ជំរុញឱ្យកម្ពុជាពិនិត្យឡើងវិញនូវអភិក្រមរបស់ខ្លួនចំពោះជំងឺកូវីដ-១៩

ទីក្រុងហ្សឺណែវ (១២ ខែមេសា ឆ្នាំ២០២១) - ក្រុមអ្នកជំនាញសិទ្ធិមនុស្សអង្គការសហប្រជាជាតិបានសម្តែងកង្វល់ជាខ្លាំង ចំពោះវិធានការច្បាប់ និងវិធានការរដ្ឋបាលថ្មីដែលមានលក្ខណៈតឹងរឹងដែលបានដាក់ចេញជាបន្តបន្ទាប់ ត្រូវបានអនុម័តដោយរាជរដ្ឋាភិបាលកម្ពុជា ក្នុងការឆ្លើយតបទៅនឹងការរាលដាលនៃជំងឺកូវីដ-១៩ ដែលប៉ះពាល់ដល់សិទ្ធិជាមូលដ្ឋាន រួមទាំងសេរីភាពក្នុងការដើរហើរ សិទ្ធិជួបប្រជុំដោយសន្តិវិធី និងសិទ្ធិការងារ។

ច្បាប់ស្តីពីវិធានការទប់ស្កាត់ការឆ្លងរាលដាលនៃជំងឺកូវីដ-១៩ និងជំងឺឆ្លងកាចសាហាវ និងប្រកបដោយគ្រោះថ្នាក់ធ្ងន់ធ្ងរផ្សេងទៀត ដែលត្រូវបានប្រកាសឱ្យប្រើកាលពីថ្ងៃទី១១ ខែមីនា អនុញ្ញាតឱ្យមានការដាក់ទោសពន្ធនាគាររយៈពេល ២០ ឆ្នាំ និងពិន័យជាប្រាក់រហូតដល់ ២០ លានរៀល (៥.000 ដុល្លារអាមេរិក) ចំពោះបុគ្គលដែលបានផ្តន្ទាទោសពីបទរំលោភបំពានលើច្បាប់នេះ។ ច្បាប់ផ្តល់សិទ្ធិអំណាចឱ្យរដ្ឋាភិបាលហាមប្រាម ឬរិតត្បិតរាល់ការប្រមូលផ្តុំ ឬការធ្វើបាតុកម្ម។ យ៉ាងហោចណាស់មានមនុស្សចំនួនបួននាក់ ត្រូវគេរាយការណ៍ថាបានចាប់ខ្លួន តាំងពីច្បាប់នេះបានចូលជាធរមាន ហើយមនុស្សមួយចំនួនទៀត ត្រូវបានបញ្ជូនទៅធ្វើចត្តាឡីស័ក។

ក្រុមអ្នកជំនាញបានមានប្រសាសន៍ថា "ការរិតត្បិតលើសេរីភាព និងសិទ្ធិជាមូលដ្ឋាន ដោយផ្អែកលើហេតុផលសុខភាពសាធារណៈ មិនត្រូវរំលោភសិទ្ធិសេរីភាព ដែលបានធានាការពារដោយច្បាប់សិទ្ធិមនុស្សអន្តរជាតិឡើយ"។ "យើងមានកង្វល់ថា វិធានការរដ្ឋបាល និងវិធានការព្រហ្មទណ្ឌ រួមទាំង ការដាក់ទោសពន្ធនាគាររយៈពេលវែងហួសហេតុ និងការពិន័យជាប្រាក់ដែលមានចែងក្នុងច្បាប់នេះ ទំនងជាមិនមានសមាមាត្រ និងមិនចាំបាច់ឡើយ។ រាល់វិធានការដែលបានចាត់ឡើងសំដៅប្រយុទ្ធប្រឆាំងនឹងការឆ្លងរាលដាន រួមទាំង ទោសទណ្ឌដែលអាចមាន គួរតែធ្វើក្នុងករណីចាំបាច់ និងមានលក្ខណៈសមាមាត្រ ហើយមិនត្រូវបានប្រើប្រាស់ហួសហេតុឡើយ"។

ទន្ទឹមនឹងកត់សម្គាល់ពីកិច្ចខិតខំប្រឹងប្រែងរបស់រដ្ឋាភិបាលក្នុងការទប់ស្កាត់ការឆ្លងរាលដាលនៃជំងឺកូវីដ-១៩ និងកម្រិតការឆ្លងក្នុងសហគមន៍ ក្រុមអ្នកជំនាញក៏បានសម្តែងការខកចិត្តផងដែរ ចំពោះការបង្ហាញព័ត៌មានផ្ទាល់ខ្លួន កាលពីពេលថ្មីៗនេះ របស់បុគ្គលដែលបានធ្វើតេស្តវិជ្ជមានកូវីដ-១៩។

ចាប់តាំងពីថ្ងៃទី០៣ ខែមេសា រដ្ឋបាលរាជធានីភ្នំពេញបានផ្សព្វផ្សាយព័ត៌មានឯកជន យ៉ាងហោចណាស់ មនុស្សចំនួន ៩៧៦ នាក់ ដែលបានធ្វើតេស្តវិជ្ជមានកូវីដ-១៩ រួមមាន ឈ្មោះ ភេទ អាយុ មុខរបរ កន្លែងធ្វើការ និងអាសយដ្ឋាន។ អាជ្ញាធរមូលដ្ឋាននៅបណ្តាខេត្តផ្សេងទៀត បច្ចុប្បន្នក៏កំពុងផ្សព្វផ្សាយព័ត៌មានផ្ទាល់ខ្លួនបុគ្គលបែបនេះដែរ។ នៅខែធ្នូ ឆ្នាំ២០២០ អាជ្ញាធរបានដកសេចក្តីសម្រេចផ្សព្វផ្សាយព័ត៌មានផ្ទាល់ខ្លួនបុគ្គល បន្ទាប់ពីក្រុមអ្នកជំនាញ អ.ស.ប បានអន្តរាគមន៍។

ក្រុមអ្នកជំនាញបានមានប្រសាសន៍ថា "ទិន្នន័យសុខភាពបុគ្គលទាំងនេះ គួរតែស្ថិតក្នុងការការពារយ៉ាងតឹងរឹងនូវសិទ្ធិឯកជន ប្រឆាំងនឹងការបង្ហាញឱ្យអ្នកដែលគ្មានការអនុញ្ញាតដឹង ក្រៅពីគោលបំណងសុខភាពសាធារណៈ។ ការលាតត្រដាងទិន្នន័យបុគ្គល រួមទាំងឈ្មោះបុគ្គលដែលឆ្លងជំងឺនេះ គឺជាការបំពានធ្ងន់ធ្ងរលើសិទ្ធិឯកជន ដែលអាចនាំឱ្យមានការរើសអើង និងការម៉ាក់ងាយ"។ "វិធានការទាំងនេះ មិនមានទំនាក់ទំនងសំខាន់ណាមួយទៅនឹងវិធានការសុខភាពសាធារណៈទេ ព្រោះថាការតាមដានរកអ្នកប៉ះពាល់ មិនចាំបាច់ត្រូវបង្ហាញព័ត៌មានឯកជន និងព័ត៌មានផ្ទាល់ខ្លួនបុគ្គលឡើយ តាមពិតទៅ ការផ្សាយព័ត៌មានបែបនេះ អាចធ្វើឱ្យប្រជាជនមិនហ៊ានចេញមកធ្វើតេស្តទៅវិញទេ។"

ក្រុមអ្នកជំនាញបានជំរុញឱ្យអាជ្ញាធរធានាថា ប្រជាជនកម្ពុជាទាំងអស់ ជាពិសេស ជនដែលស្ថិតក្នុងស្ថានភាពបាត់បង់ឱកាស និង ងាយរងគ្រោះ មានសិទ្ធិទទួលបានទំនិញ សេវា និងបន្ទប់ជាក់លាក់សម្រាប់សម្រាកព្យាបាលជំងឺកូវីដ-១៩ ដោយដោយគ្មានការរើសអើង ឬការម៉ាក់ងាយ។

ក្រុមអ្នកជំនាញបានជំរុញផងដែរ ឱ្យរដ្ឋាភិបាលផ្តល់ជំនួយសេដ្ឋកិច្ច ដល់ប្រជាពលរដ្ឋដែលរងផលប៉ះពាល់ដោយវិបត្តិនេះ។ នៅថ្ងៃទី០១ ខែមេសា អាជ្ញាធរបានដាក់បម្រាមគោចររយៈពេល ២ សប្តាហ៍ នៅរាជធានីភ្នំពេញ ដែលរដ្ឋាភិបាលបានអះអាងថា ក្នុងគោលបំណងផ្អាកជាបណ្តោះអាសន្ននូវការធ្វើអាជីវកម្ម ការប្រមូលផ្តុំ និងការធ្វើដំណើរ "ដែលមិនចាំបាច់"។ រដ្ឋាភិបាលក៏បានប្រកាសហាមប្រាមការធ្វើដំណើរឆ្លងខេត្ត ចាប់ពីថ្ងៃទី០៧ ដល់ថ្ងៃទី២០ ខែមេសា ដែលជារយៈពេលមួយគ្របដណ្តប់លើថ្ងៃឈប់សម្រាកបុណ្យចូលឆ្នាំថ្មីប្រពៃណីខ្មែរ។

ក្រុមអ្នកជំនាញបានមានប្រសាសន៍ថា "ដោយពិចារណាទៅលើការកើនឡើងនៃបំណុលនៅកម្ពុជា វិធានការទាំងនេះរឹតតែធ្វើឱ្យប៉ះពាល់ថែមទៀតដល់ប្រជាជនដែលស្ថិតក្នុងស្ថានភាពងាយរងគ្រោះបំផុត ដែលពួកគេបានទទួលរងស្រាប់ហើយនូវការលំបាកផ្នែកសេដ្ឋកិច្ច ក្នុងអំឡុងពេលមានការឆ្លងរាលដាលនៃជំងឺកូវីដ-១៩ នេះ។ វាជាហានិភ័យក្នុងការរុញច្រានពួកគេឱ្យធ្លាក់ក្នុងភាពក្រីក្រ"។

ក្រុមអ្នកជំនាញបានមានប្រសាសន៍ថា "អ្នកដែលនឹងត្រូវទទួលរងផលប៉ះពាល់បំផុតគឺជាអ្នកដែលធ្វើការក្នុងវិស័យក្រៅប្រព័ន្ធ មានជាអាទិ៍ អ្នករត់រ៉ឺម៉កម៉ូតូកង់បី និងអ្នកលក់ដូរតាមចិញ្ចើមផ្លូវ"។

"រដ្ឋាភិបាលគួរតែធានាថា វិធានការសង្គ្រោះសេដ្ឋកិច្ចរបស់ខ្លួន ផ្តោតគោលដៅលើក្រុមទាំងនេះ ហើយថាប្រជាជនដែលស្ថិតក្នុងស្ថានភាពងាយរងគ្រោះបំផុត ត្រូវបានផ្តល់ការគាំទ្រគ្រប់គ្រាន់ ដើម្បីអាចដោះស្រាយការលំបាក នៅក្នុងអំឡុងពេលមានវិធានការទប់ស្កាត់ការឆ្លងរាលដាល។"

**ចប់**

***ក្រុមអ្នកជំនាញ អ.ស.ប៖ លោកស្រី រ៉ូណា ស្មីត* (Ms. Rhona Smith)** *អ្នករាយការណ៍ពិសេសស្តីពីស្ថានភាពសិទ្ធិមនុស្សនៅកម្ពុជា,* ***លោក ក្លេម៉ង់ត៍ នីយ៉ាលេតសូស្សី វ៉ូលេ* (Mr Clement Nyaletsossi Voule)** *អ្នករាយការណ៍ពិសេសស្តីពីសិទ្ធិជួបជុំដោយសន្តិវិធី និងសិទ្ធិសមាគម,* ***លោក ចូសិប ខាណាតាស៊ី* (Mr Joseph Cannataci)** *អ្នករាយការណ៍ពិសេសស្តីពីសិទ្ធិឯកជន,* ***លោក ត្លាលេង ម៉ូហ្វូកេង* (Tlaleng Mofokeng)** *អ្នករាយការណ៍ពិសេសស្តីពីសិទ្ធិជនគ្រប់រូបក្នុងការទទួលបានកម្រិតជីវភាពរស់នៅខ្ពស់បំផុតផ្នែកសុខភាពផ្លូវកាយ និងសុខភាពផ្លូវចិត្ត។*

*អ្នករាយការណ៍ពិសេស គឺជាផ្នែកមួយនៃអ្វីដែលគេស្គាល់ថាជានីតិវិធីពិសេសនៃក្រុមប្រឹក្សាសិទ្ធិមនុស្ស។ នីតិវិធីពិសេស (ស្ថាប័នដ៏ធំបំផុតមួយនៃអ្នកជំនាញឯករាជ្យនៅក្នុងប្រព័ន្ធសិទ្ធិមនុស្ស អ.ស.ប) គឺជាឈ្មោះទូទៅមួយនៃយន្តការឃ្លាំមើល និងស្វែងរកការពិតឯករាជ្យរបស់ក្រុមប្រឹក្សានេះ ដែលដោះស្រាយស្ថានភាពសិទ្ធិមនុស្សរបស់ប្រទេសមួយជាក់លាក់ ឬបញ្ហាសិទ្ធិមនុស្សតាមវិស័យនីមួយៗ នៅគ្រប់តំបន់ទាំងអស់នៃពិភពលោក។ ក្រុមអ្នកជំនាញនៃនីតិវិធីពិសេស ធ្វើការផ្អែកលើគោលការណ៍ស្ម័គ្រចិត្ត ពួកគាត់មិនមែនជាបុគ្គលិក អ.ស.ប ទេ ហើយមិនទទួលប្រាក់បៀវត្សរ៍សម្រាប់ការងាររបស់ខ្លួនឡើយ។ ពួកគេធ្វើការឯករាជ្យពីរដ្ឋាភិបាល ឬអង្គការណាមួយ ហើយបម្រើការក្នុងសមត្ថភាពបុគ្គលផ្ទាល់របស់ខ្លួន។*

*សិទ្ធិមនុស្ស អ.ស.ប គេហទំព័រសម្រាប់ប្រទេស - កម្ពុជា*

*សម្រាប់ព័ត៌មានបន្ថែម និង**ការសាកសួរព័ត៌មានផ្សេងៗ** សូមទាក់ទង៖*
***លោក ម៉ាស័មូដ ហ្គារហ្គា*** *(Mahmoud Garga) តាមរយៈទូរស័ព្ទលេខ៖ (+៨៥៥ (0)១២ ៧៩០ ១៧៨ ឬ អ៊ីម៉ែល mgarga@ohchr.org) ឬ* ***លោក ណាវីដ អាមេដ (Mr Naveed Ahmad)*** *តាមរយៈអ៊ីម៉ែល Nahmed@ohchr.org)*

*សម្រាប់ការសាកសួរព័ត៌មានទាក់ទងនឹងអ្នកជំនាញឯករាជ្យដទៃផ្សេងទៀតរបស់អង្គការសហប្រជាជាតិ សូមទាក់ទង* ***លោក រ៉ូណាតូ ឌឺ សូហ្សា*** *(Renato de Souza) តាមរយៈទូរស័ព្ទលេខ (+៤១ ២២ ៩២៨ ៩៨៥៥ / ឬ អ៊ីម៉ែល rrosariodesouza@ohchr.org)*

*តាមដានព័ត៌មានទាក់ទងនឹងក្រុមអ្នកជំនាញសិទ្ធិមនុស្សឯករាជ្យរបស់ អ.ស.ប តាមបណ្តាញទ្វីធទ័រ Twitter@UN_SPExperts*

*តើអ្នកមានកង្វល់អំពីពិភពលោកដែលយើងរស់នៅឬទេ?*
***បើអ្នកមានកង្វល់ ក្រោកឈរ ដើម្បីសិទ្ធិនរណាម្នាក់នៅថ្ងៃនេះ។***
*ហើយចូលទៅកាន់គេហទំព័រ http://www.standup4humanrights.org*